# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ៧៦១៧
មកដល់ថ្ងៃទី២១ ខែ១១ ឆ្នាំ១៩
ម៉ោង ៩:០៩

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

# របបសន្តិសុខសង្គម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២/៣១

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .. គោលបំណង**

ច្បាប់នេះមានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឲ្យមានសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។

**មាត្រា២ .. គោលដៅ**

ច្បាប់នេះមានគោលដៅកំណត់អំពីគោលការណ៍ទូទៅ បែបបទ យន្តការអនុវត្តនិងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។

**មាត្រា៣ .. វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងអស់ដូចខាងក្រោម៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈរួមមាន៖

- មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- មន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ លើកលែងផ្នែកប្រាក់សោធន
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ
- មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ចំពោះតែតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងផ្នែកថែទាំសុខភាព
- មន្ត្រីដែលបម្រើការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងអាជ្ញាធរសវនកម្មជាតិ
- អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ
- បុគ្គលនៃវិស័យសាធារណៈផ្សេងទៀត ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣. បុគ្គលស្វ័យនិយោជន៍។

ច្បាប់នេះមិនមានវិសាលភាពអនុវត្តលើយោធិននៃកងយោធពលខេមរភូមិន្ទ ដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ – និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានកំណត់និយមន័យដូចមានចែងនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម

**មាត្រា៥ – ផ្នែកប្រាក់សោធន**

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋនិងបុគ្គលនៃវិស័យសាធារណៈមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ – ផ្នែកថែទាំសុខភាព**

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋ បុគ្គលនៃវិស័យសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧ – ផ្នែកហានិភ័យការងារ**

របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវា

សមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៨ .- ផ្នែកនិកម្មភាពការងារ**

របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងកម្មករនិយោជិតត្រូវមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៩ .- ចំណែកនៃភាគទានសម្រាប់របបភាគទានជាកាតព្វកិច្ច**

ចំណែកនៃភាគទានរបស់បុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះសម្រាប់របបភាគទានជាកាតព្វកិច្ច ក្នុងផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព និងនិកម្មភាពការងារមិនត្រូវលើសពី៥០%(ហាសិបភាគរយ)នៃភាគទានសរុបឡើយ។

ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទានត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា១០ .- ក្រុមប្រឹក្សាជាតិគាំពារសង្គម**

រាល់ប្រតិបត្តិការសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និងតម្រង់ទិសក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១១ .- និយ័តករសន្តិសុខសង្គម**

ត្រូវបានបង្កើតនិយ័តករសន្តិសុខសង្គមដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

១. កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ វិធានចាំបាច់នានា និងគោលការណ៍ណែនាំស្តីពីវិនិយោគមូលនិធិសន្តិសុខសង្គម។

២. តាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។

៣. បង្កើតយន្តការការពារសមាជិកនិងផ្សះផ្សាវិវាទនៅពេលមានទំនាស់។

៤. ត្រួតពិនិត្យអនុលោមភាព ដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១២ .- បេឡាជាតិសន្តិសុខសង្គម**

បេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា ប.ស.ស. ជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

ប.ស.ស. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបង្កើតដោយព្រះរាជក្រឹត្យ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.- ភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម**

ប.ស.ស. មានភារកិច្ចដូចខាងក្រោម៖

១. គ្រប់គ្រងនិងចាត់ចែងផ្នែកទាំងអស់នៃរបបសន្តិសុខសង្គមដែលកំណត់ដោយច្បាប់នេះ។

២. ធានាផ្តល់ការការពារសន្តិសុខសង្គមសម្រាប់សមាជិក ប.ស.ស. ក្នុងគោលដៅជួយសម្រាលការលំបាកក្នុងជីវភាពនៅពេលជួបប្រទះហានិភ័យជាយថាហេតុនានា ជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និកម្មភាពការងារ មាតុភាព ជំងឺ ឬគ្រោះថ្នាក់ ព្រមទាំងយថាភាពដទៃផ្សេងទៀត។

៣. ប្រមូលនិងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗព្រមទាំងប្រភពចំណូលដទៃផ្សេងទៀត។

៤. ចុះបញ្ជីនិងគ្រប់គ្រងលេខសម្គាល់សមាជិក ប.ស.ស.។

៥. ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ដោយសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ប.ស.ស.។

៦. អប់រំ ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការហានិភ័យការងារ និងបង្ការសុខភាពសម្រាប់សមាជិក ប.ស.ស.។

៧. សិក្សា ស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។

៨. សិក្សា ស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។

៩. ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

១០. សិក្សា វិភាគ និងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

១១. អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាពនិងសង្គម ដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃសមាជិក ប.ស.ស.។

១២. ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

**មាត្រា១៤.- ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម**

ប.ស.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - តំណាងក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - តំណាងនិយោជក២រូប | សមាជិក |
| - តំណាងសមាជិក ប.ស.ស. ២រូប | សមាជិក |
| - អគ្គនាយក ប.ស.ស. | សមាជិកអចិន្ត្រៃយ៍។ |

**មាត្រា១៥ .. អង្គភាពប្រតិបត្តិនៃបេឡាជាតិសន្តិសុខសង្គម**

ប.ស.ស. ត្រូវចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃដោយអគ្គនាយក១(មួយ)រូបដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអគ្គនាយករងមួយចំនួនជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ប.ស.ស. ដែលមានកំណត់ក្នុងច្បាប់នេះ ជាសមត្ថកិច្ចរបស់អធិការសន្តិសុខសង្គម។ ការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

បុគ្គលិករបស់ ប.ស.ស. ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានផ្ទេរឬជ្រើសរើសថ្មីតាមសំណើរបស់អគ្គនាយកនៃ ប.ស.ស. និងបុគ្គលិកជាប់កិច្ចសន្យាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកនៃ ប.ស.ស. ស្របតាមច្បាប់ស្តីពីការងារ។

**មាត្រា១៦ .. ការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម**

ការគ្រប់គ្រងមូលនិធិរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស.។ ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ត្រូវរៀបចំគោលការណ៍នៃការគ្រប់គ្រងមូលនិធិ ការគ្រប់គ្រងការវិនិយោគ ផែនការវិនិយោគ និងកញ្ចប់វិនិយោគដាក់ជូនក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ពិនិត្យនិងអនុម័តដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម ដើម្បីស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងការបំពេញតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ត្រូវធ្វើរបាយការណ៍ស្តីពីការរក្សានិងការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមគ្រប់ផ្នែកជូនក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. និយ័តករសន្តិសុខសង្គម និងអគ្គនាយកនៃ ប.ស.ស. ជាទៀងទាត់។

សមាសភាព គុណវុឌ្ឍិ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤

## របបសន្តិសុខសង្គមផ្នែកប្រាក់សោធន

## ផ្នែកទី១

## គោលការណ៍រួម

**មាត្រា១៧ .. បុគ្គលត្រូវគាំពារ**

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកប្រាក់សោធនមានដូចខាងក្រោម៖

១- បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ។

២- បុគ្គលិកទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣- បុគ្គលស្វ័យនិយោជន៍។

**មាត្រា១៨ – ការកាលិកផ្នែកប្រាក់សោធន**

ការកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច រួមមាន សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍បូជាសព។

ការកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៩ – ភាគទានផ្នែកប្រាក់សោធន**

អត្រាភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រាភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រាភាគទានផ្នែកប្រាក់សោធនត្រូវដំឡើងតាមវិធីសាស្រ្តបុព្វលាភជណ្តើរឬវិធីសាស្រ្តសមស្របមួយដែលអនុម័តដោយក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២០ – សិទ្ធិវន្តនៃសោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវី រួមមាន សហព័ទ្ធនិងកូននៅក្នុងបន្ទុកផ្ទាល់របស់សាមីជនដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មិនមានប្រកបការងារឬមុខរបរមានប្រាក់ចំណូលលើបន្ទាត់នៃភាពក្រីក្រ។

២. ចំពោះសហព័ទ្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទដែលសាមីជនធ្លាក់ខ្លួនឈឺឬគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្តាលឲ្យទទួលមរណភាព។

៣. ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មិនទាន់រៀបអាពាហ៍ពិពាហ៍
- មានអាយុមិនលើសពី១៨(ដប់ប្រាំបី)ឆ្នាំ

កូនពិការឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារឬមុខរបរដែលមានប្រាក់ចំណូល ត្រូវផ្តល់សោធនឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្រ្តនៃប.ស.ស.។ ក្រុមប្រឹក្សាវេជ្ជសាស្រ្តនៃ ប.ស.ស. អាចវាយតម្លៃឡើងវិញលើស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃ ក្នុងករណីចាំបាច់។

សិទ្ធិទទួលបានសោធនឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- សិទ្ធិវន្តទទួលមរណភាព
- សហព័ទ្ធរៀបអាពាហ៍ពិពាហ៍ជាថ្មីស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក ប.ស.ស.យ៉ាងយូរ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី។

**មាត្រា២១ – ប្រភពធនធានផ្នែកប្រាក់សោធន**

ធនធានផ្នែកប្រាក់សោធនមានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក ប.ស.ស.
- ផលដែលបានមកពីការវិនិយោគ

-អំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។

**មាត្រា២២ - ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធនត្រូវធ្វើការត្រួតពិនិត្យនិងវិភាគឡើងវិញយ៉ាងយូរ៥(ប្រាំ)ឆ្នាំម្តង។

**មាត្រា២៣ - ការកែសម្រួលតាវកាលិកផ្នែកប្រាក់សោធន**

តាវកាលិកផ្នែកប្រាក់សោធនត្រូវកែសម្រួលរៀងរាល់ឆ្នាំស្របតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ។

**មាត្រា២៤ - ប្រាក់ត្រៀមបម្រុងផ្នែកប្រាក់សោធន**

ប្រាក់ត្រៀមបម្រុងផ្នែកប្រាក់សោធនត្រូវកំណត់ស្មើនឹងប្រាក់ចំណាយសម្រាប់តាវកាលិកផ្នែកប្រាក់សោធនក្នុងកំលុងពេល៣(បី)ឆ្នាំចុងក្រោយ។

**មាត្រា២៥ - ការកំណត់ស្ថានភាពទុព្វលភាព**

ស្ថានភាពទុព្វលភាពត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស.។ ការពិនិត្យឡើងវិញអំពីស្ថានភាពទុព្វលភាពត្រូវធ្វើជារៀងរាល់ឆ្នាំ។ សោធនទុព្វលភាពត្រូវបានព្យួរក្នុងករណីសាមីខ្លួនមិនបានចូលខ្លួនមកពិនិត្យសុខភាពតាមកាលកំណត់។

## ផ្នែកទី២

## ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច

### កថាភាគទី១

### ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច សម្រាប់បុគ្គលនៃវិស័យសាធារណៈ

**មាត្រា២៦ - សោធនជរាភាព**

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈទាំងពីរភេទត្រូវដាក់ឲ្យចូលនិវត្តន៍ ជាកំហិត ពេលដល់អាយុ៦០(ហុកសិប)ឆ្នាំ និងមានសិទ្ធិទទួលសោធនជរាភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២- បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។

សមាជិក ប.ស.ស. ដែលមិនបានបំពេញលក្ខខណ្ឌក្នុងចំណុចទី២នៃកថាខណ្ឌទី១ខាងលើត្រូវទទួលបានវិភាជន៍ជរាភាព។

អាយុចូលនិវត្តន៍របស់បុគ្គលនៃវិស័យសាធារណៈទាំងពីរភេទអាចត្រូវបានកែប្រែដោយព្រះរាជក្រឹត្យ អាស្រ័យដោយការប្រែប្រួលនៃអាយុរំពឹងទុក ស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ច។

**មាត្រា២៧ - សោធនទុព្វលភាព**

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈដែលធ្លាក់ខ្លួនក្នុងទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២- បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព។

**មាត្រា២៨ .- សោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវីត្រូវទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាពឬទុព្វលភាព ឬសមាជិក ប.ស.ស. ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។

អត្រាសោធនឧត្តរជីវីអប្បបរមាត្រូវកំណត់ស្មើនឹង៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់សោធនជរាភាពឬទុព្វលភាពរបស់សាមីជន។

ចំណែកសោធនឧត្តរជីវីត្រូវបានបែងចែកដូចខាងក្រោម៖

- សម្រាប់សហព័ទ្ធ៥០%(ហាសិបភាគរយ)
- សម្រាប់កូន៥០%(ហាសិបភាគរយ)
- ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធឬកូន ត្រូវទទួលបាន១០០%(មួយរយភាគរយ)។

**មាត្រា២៩ .- វិភាជន៍បូជាសព**

សិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាពឬទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីយកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធនឧត្តរជីវី វិភាជន៍បូជាសពអាចត្រូវបានផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជាសពសាមីជនផ្ទាល់។

**មាត្រា៣០ .- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធន សម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## កថាភាគទី២

## ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

**មាត្រា៣១ .- សោធនជរាភាព**

សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលមានអាយុយ៉ាងតិច៦០(ហុកសិប)ឆ្នាំ មានសិទ្ធិទទួលសោធនជរាភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- មានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២- បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច១២(ដប់ពីរ)ខែ។

សមាជិក ប.ស.ស. ដែលមិនបានបំពេញលក្ខខណ្ឌក្នុងចំណុចទី២នៃកថាខណ្ឌទី១ខាងលើ ត្រូវទទួលបានវិភាជន៍ជរាភាពដែលត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រា[illegible]ច័យជរាភាពអតិបរមាស្មើនឹង១,៧៥%(មួយក្បៀសចិតសិបប្រាំភាគរយ)ក្នុង

មួយឆ្នាំភាគទាន។ អត្រាសមាច័យសោធនជរាភាពនេះត្រូវកំណត់ដោយអនុក្រឹត្យ។

សោធនជរាភាពត្រូវគណនាជាអនុគមន៍នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួន។

**មាត្រា៣២ _ សោធនទុព្វលភាព**

សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលធ្លាក់ខ្លួនក្នុងទុព្វលភាព មានសិទ្ធិទទួលបានសោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន។

២. បានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព។

អត្រាសមាច័យទុព្វលភាពអតិបរមាស្មើនឹង១,៧៥%(មួយក្បៀសចិតសិបប្រាំភាគរយ) ក្នុងមួយឆ្នាំភាគទាន។ កម្រិតអប្បបរមានៃសោធនទុព្វលភាពត្រូវស្មើនឹង៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីជន។ អត្រាសមាច័យសោធនទុព្វលភាពនេះត្រូវកំណត់ដោយអនុក្រឹត្យ។

សោធនទុព្វលភាពត្រូវគណនាជាអនុគមន៍នៃប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទានរបស់សាមីខ្លួន។

**មាត្រា៣៣ _ សោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវីត្រូវទទួលបានសោធនឧត្តរជីវី លុះត្រាតែមានការទទួលមរណភាពនៃសាមីជនជាសោធនិកជរាភាពឬទុព្វលភាព ឬសមាជិក ប.ស.ស. ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៦០(ហុកសិប)ខែ។

អត្រាសោធនឧត្តរជីវីអប្បបរមាត្រូវកំណត់ស្មើនឹង៤៥%(សែសិបប្រាំភាគរយ)នៃប្រាក់សោធនជរាភាពឬទុព្វលភាពរបស់សាមីជន។

ចំណែកសោធនឧត្តរជីវីត្រូវបានបែងចែកដូចខាងក្រោម៖

- សម្រាប់សហព័ទ្ធ៥០%(ហាសិបភាគរយ)
- សម្រាប់កូន៥០%(ហាសិបភាគរយ)
- ក្នុងករណីដែលសិទ្ធិវន្តមានតែសហព័ទ្ធឬកូន ត្រូវទទួលបាន១០០%(មួយរយភាគរយ)។

**មាត្រា៣៤ _ វិភាជន៍បូជាសព**

សិទ្ធិវន្តនៃសោធនឧត្តរជីវីមានសិទ្ធិទទួលបានវិភាជន៍បូជាសព នៅពេលដែលសោធនិកជរាភាពឬទុព្វលភាពសាមីទទួលមរណភាព។ ប្រសិនបើករណីយកិច្ចនេះមិនបានបំពេញដោយសិទ្ធិវន្តនៃសោធនឧត្តរជីវី វិភាជន៍បូជាសពអាចត្រូវបានផ្តល់ដល់ជនណាដែលជាអ្នកចាត់ចែងបូជា[illegible]សាមីជនផ្ទាល់។

វិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។

# ផ្នែកទី៣
# ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត
## កថាភាគទី១
## ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ
### មាត្រា៣៥.- លក្ខខណ្ឌនិងសិទ្ធិនៃការចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ
- មានលទ្ធភាពបង់ភាគទានបន្ត។

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានអាយុគ្រប់៦០(ហុកសិប)ឆ្នាំនិងមានបំណងបង់ភាគទានបន្ត ដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្ដែង ដែលសាមីខ្លួនត្រូវទទួលបានតាមរបបភាគទានជាកាតព្វកិច្ច អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន។ ក្នុងករណីនេះ សោធនជរាភាពត្រូវបើកផ្ដល់តាមកាលបរិច្ឆេទជាក់លាក់ ដែលសាមីខ្លួនអស់លទ្ធភាពចូលរួមក្នុងផ្នែកនេះ។

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតានដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបាន។ ការបង់ភាគទានក្នុងផ្នែកនេះត្រូវអនុវត្តចំពោះតែចំណែកនៃប្រាក់ឈ្នួលដែលខ្ពស់ជាងប្រាក់ឈ្នួលពិតានតាមប្រព័ន្ធហិរញ្ញប្បទានពេញលេញ។

ការបង់ភាគទានផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តជាបន្ទុកផ្ទាល់របស់សាមីជន។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## កថាភាគទី២
## ផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍

**មាត្រា៣៦ – លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត**

បុគ្គលស្វ័យនិយោជន៍អាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដែលត្រូវកំណត់ដោយអនុក្រឹត្យ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចូលរួមសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

## កថាភាគទី៣
## ផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលនៃវិស័យសាធារណៈ

**មាត្រា៣៧ – លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត**

បុគ្គលនៃវិស័យសាធារណៈអាចចូលរួមក្នុងផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត។

យន្តការនៃការកំណត់អត្រាភាគទានក្នុងផ្នែកនេះត្រូវអនុវត្តដូចគ្នានឹងផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចូលរួមដោយស្ម័គ្រចិត្តសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី៥
# របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
## ផ្នែកទី១
## គោលការណ៍រួម

**មាត្រា៣៨ – បុគ្គលត្រូវគាំពារ**

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកថែទាំសុខភាព រួមមាន៖

១- បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ។

២- បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣- បុគ្គលស្វ័យនិយោជន៍។

**មាត្រា៣៩ – តាវកាលិកផ្នែកថែទាំសុខភាព**

តាវកាលិកផ្នែកថែទាំសុខភាពរួមមាន៖

- ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ

- ប្រាក់បំណាច់មាតុភាព និង
- វិភាជន៍បូជាសព។

**មាត្រា៤០.- ភាគទានថែ្ទកថែទាំសុខភាព**

អត្រាភាគទានថែ្ទកថែទាំសុខភាពត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤១.- ប្រភពធនធានថែ្ទកថែទាំសុខភាព**

ធនធានថែ្ទកថែទាំសុខភាពមានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក ម.ស.ស.
- ផលដែលបានមកពីការវិនិយោគ
- អំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។

**មាត្រា៤២.- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃថែ្ទកថែទាំសុខភាពត្រូវធ្វើការត្រួតពិនិត្យ និងវិភាគឡើងវិញជារៀងរាល់ឆ្នាំ។

**មាត្រា៤៣.- ការពិនិត្យកែសម្រួលតាមកាលិកថែ្ទកថែទាំសុខភាព**

ការកាលិកថែ្ទកថែទាំសុខភាពត្រូវធ្វើការពិនិត្យកែសម្រួលស្របតាមស្ថានភាពថែ្ទកសុខាភិបាលជាក់ស្តែង។

យន្តការទូទាត់ថ្លៃសេវាថែ្ទកថែទាំសុខភាពត្រូវអនុលោមតាមយន្តការទូទាត់ថ្លៃតាមករណី និង/ឬតាមថ្លៃសេវា។ ការកែប្រែយន្តការទូទាត់ថ្លៃសេវាថែ្ទកថែទាំសុខភាពតាមយន្តការដទៃផ្សេងទៀតត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៤.- ប្រាក់ត្រៀមបម្រុងថែ្ទកថែទាំសុខភាព**

ប្រាក់ត្រៀមបម្រុងអប្បបរមាថែ្ទកថែទាំសុខភាពត្រូវស្មើនឹងប្រាក់ចំណាយសម្រាប់ការកាលិកថែ្ទកថែទាំសុខភាពក្នុងកំលុងពេល១(មួយ)ឆ្នាំចុងក្រោយ។

**មាត្រា៤៥.- ការទទួលស្គាល់មូលដ្ឋានសុខាភិបាល**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាលនិងបានចុះកិច្ចព្រមព្រៀងជាមួយ ម.ស.ស.។

**មាត្រា៤៦.- ការត្រួតពិនិត្យគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល**

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងសុខាភិបាល។

**មាត្រា៤៧.- ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម**

ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ម.ស.ស. មានតួនាទីត្រួតពិនិត្យ តាមដាន ការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ម.ស.ស.។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ម.ស.ស. ត្រូវកំណត់ដោយអនុក្រឹត្យ។

# ផ្នែកទី២
# ផ្នែកថែទាំសុខភាពតាមរបបភាគទានជាភាគពុកិច្ច
## កថាភាគទី១
## ផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ

### មាត្រា៤៨.- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ លុះត្រាតែបានចុះបញ្ជីនិងបង់ភាគទានក្នុងផ្នែកថែទាំសុខភាព។

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រមានដូចខាងក្រោម៖

១. ការផ្ដល់សេវាព្យាបាលដោយសម្រាកក្នុងមូលដ្ឋានសុខាភិបាលដែលរួមមាន៖
- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល។

២. ការផ្ដល់សេវាពិគ្រោះជំងឺក្រៅដែលរួមមាន៖
- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

៣. ការផ្ដល់សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល។

៤. ការផ្ដល់សេវាព្យាបាលដោយស្ដារ ដោយចលនា ឬសេវាស្ដារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត។

៥. ការផ្ដល់សេវាសង្គ្រោះបន្ទាន់។ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស. សាមីជនឬអ្នកតំណាងត្រូវជូនដំណឹងបន្ទាន់មក ប.ស.ស.។

៦. ការផ្ដល់សេវាបង្ការសុខភាព។

៧. ការផ្ដល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះនិងសេវាបញ្ជូនសព។

ការផ្ដល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះត្រូវផ្ដល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់និងដោយប្រើប្រាស់យន្តយានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។

ការផ្ដល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជាឬសេវាបញ្ជូនសពត្រូវផ្ដល់តាមតម្លៃរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.។

៨. សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ។

ការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ សម្រាប់គាំទ្រដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ឬសម្រាប់ជួយសម្រួលដល់អ្នកជំងឺឬជនរងគ្រោះក្នុងកំលុងពេលសម្រាកព្យាបាល។

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រដូចមានចែងក្នុងចំណុចទី១ ទី២ ទី៣ និងទី៤ ខាងលើ ត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀត មិនត្រូវបានផ្តល់ជូនឡើយ វៀរលែងតែករណីសង្គ្រោះបន្ទាន់។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាស្តារនីតិសម្បទា ការកំណត់សេវា ឬការព្យាបាល និងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូលនូវការផ្តល់សេវាបង្ការសុខភាពនិងការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

**មាត្រា៤៩.- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ**

ក្នុងរយៈពេលនៃការសម្រាកព្យាបាលជំងឺ បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈត្រូវបានរក្សាប្រាក់បៀវត្សដដែល។

**មាត្រា៥០.- ប្រាក់បំណាច់មាតុភាព**

បុគ្គលនៃវិស័យសាធារណៈជាស្ត្រីមានសិទ្ធិទទួលបានប្រាក់បៀវត្សពេញក្នុងរយៈពេលសម្រាកមាតុភាពឬក្នុងរយៈពេលព្យាបាលថែទាំសុខភាពមុននិងក្រោយពេលសម្រាលដូចមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥១.- វិភាជន៍បូជាសព**

វិភាជន៍បូជាសពត្រូវបានផ្តល់ដល់សិទ្ធិវន្តនៃសមាជិក ប.ស.ស. ដែលទទួលមរណភាពដោយសារជំងឺឬគ្រោះថ្នាក់ជាយថាហេតុ ដែលមិនពាក់ព័ន្ធនឹងការងារ។

វិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។

**មាត្រា៥២.- សុពលភាពនៃការទទួលបានសេវាផ្នែកថែទាំសុខភាព**

សុពលភាពនៃការទទួលបានសេវាផ្នែកថែទាំសុខភាព សម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

## កថាភាគទី២
## ផ្នែកថែទាំសុខភាព
## សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

**មាត្រា៥៣.- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវអនុវត្តដូចគ្នានឹងការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈដូចមានចែងក្នុងមាត្រា៤៨នៃច្បាប់នេះ។

**មាត្រា៥៤.- ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ**

សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ លុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព
- បានបង់ភាគទាន២(ពីរ)ខែជាប់គ្នាឬ៦(ប្រាំមួយ)ខែ ក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ
- បានសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលចាប់ពី៤(ប្រាំបី)ថ្ងៃឡើង។

ប្រាក់បំណាច់ប្រចាំថ្ងៃត្រូវផ្តល់ដោយគិតពីថ្ងៃផ្អាកការងារដំបូង ដោយការចូលសម្រាកព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាល។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលត្រូវកំណត់ស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានសម្រាប់រយៈពេលជាក់ស្តែងមិនលើស៦(ប្រាំមួយ)ខែ មុនខែដែលមានបញ្ហាសុខភាព។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលព្យាបាលជំងឺត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។

**មាត្រា៥៥.- ប្រាក់បំណាច់មាតុភាព**

សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះជាស្ត្រី មានសិទ្ធិទទួលបានប្រាក់បំណាច់មាតុភាព លុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព

- បានបង់ភាគទានយ៉ាងតិច៤(បួន)ខែក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយគិតមកទល់កាលបរិច្ឆេទនៃការសម្រាលកូន។

ប្រាក់បំណាច់មាតុភាពត្រូវកំណត់ស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃជាប់ភាគទានក្នុងរយៈពេលជាក់ស្តែងមិនលើស៦(ប្រាំមួយ)ខែ មុនខែសម្រាលកូន ចំនួន៩០(កៅសិប)ថ្ងៃ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់បំណាច់មាតុភាពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។

## ផ្នែកទី៣

## ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត

### មាត្រា៥៦ – លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្ត

បុគ្គលស្វ័យនិយោជន៍អាចចូលរួមក្នុងផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តក្នុងផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

## ផ្នែកទី១

## គោលការណ៍រួម

### មាត្រា៥៧ – បុគ្គលត្រូវគាំពារ

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកហានិភ័យការងារ រួមមាន៖

១. បុគ្គលនៃវិស័យសាធារណៈ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

### មាត្រា៥៨ – តាវកាលិកផ្នែកហានិភ័យការងារ

តាវកាលិកផ្នែកហានិភ័យការងារ រួមមាន ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ការផ្តល់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ការផ្តល់ធនលាភឧត្តរជីវី វិភាជន៍បូជាសព និងការផ្តល់សេវាស្តារនីតិសម្បទា។

ចំពោះគ្រោះថ្នាក់បង្កឡើងដោយចេតនាផ្ទាល់ខ្លួន មិនត្រូវទទួលបានតាវកាលិកផ្នែកហានិភ័យការងារទេ។

### មាត្រា៥៩ – ភាគទានផ្នែកហានិភ័យការងារ

អត្រាភាគទានផ្នែកហានិភ័យការងារត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦០.- ប្រភពធនធានផ្នែកហានិភ័យការងារ**

ធនធានផ្នែកហានិភ័យការងារ មានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋនិងនិយោជក
- ផលដែលបានមកពីការវិនិយោគ
- អំណោយឬអច្ច័យទាននិងប្រភពស្របច្បាប់ដទៃផ្សេងទៀត។

**មាត្រា៦១.- ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុ**

ការគណនាវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកហានិភ័យការងារត្រូវធ្វើការត្រួតពិនិត្យនិងវិភាគឡើងវិញយ៉ាងយូរ៣(បី)ឆ្នាំម្តង។

**មាត្រា៦២.- ការកែសម្រួលតាវកាលិកផ្នែកហានិភ័យការងារ**

តាវកាលិកផ្នែកហានិភ័យការងារជាធនលាភត្រូវធ្វើការពិនិត្យនិងកែសម្រួលស្របតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ផ្លូវការ។

យន្តការទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារសម្រាប់មូលដ្ឋានសុខាភិបាល ត្រូវអនុលោមតាមយន្តការទូទាត់ថ្លៃតាមសេវា។ ការកែប្រែយន្តការទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៣.- ប្រាក់ត្រៀមបម្រុងផ្នែកហានិភ័យការងារ**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកហានិភ័យការងារត្រូវស្មើនឹងប្រាក់ចំណាយសម្រាប់ធនលាភដែលបានផ្តល់រួច បូកនឹង៥០%(ហាសិបភាគរយ)នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃផ្សេងពីធនលាភក្នុងកំលុងពេល២(ពីរ)ឆ្នាំចុងក្រោយ។

**មាត្រា៦៤.- ការទទួលស្គាល់មូលដ្ឋានសុខាភិបាល**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

**មាត្រា៦៥.- ការត្រួតពិនិត្យគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល**

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងសុខាភិបាល។ គុណភាពសេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដានវាយតម្លៃរបស់ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.**។

**មាត្រា៦៦.- កាតព្វកិច្ចរាយការណ៍ហានិភ័យការងារ**

ជនរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ឬក៏អ្នកតំណាងជនរងគ្រោះ ត្រូវជូនដំណឹងជាបន្ទាន់ទៅ **ប.ស.ស.** និយោជក ឬអ្នកតំណាងនិយោជក អំពីគ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ។

បែបបទនៃការជូនដំណឹងពីហានិភ័យការងារ ការអង្កេតហានិភ័យការងារ និងការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចរបស់និយោជក មូលដ្ឋានសុខាភិបាល និងជនរងគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកកិច្ចការរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.**។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS

តារាងជំងឺវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៧ ‑ កម្មវិធីបង្ការហានិភ័យការងារ**

ប.ស.ស. ត្រូវរៀបចំឲ្យមានកម្មវិធីបង្ការហានិភ័យការងារ ដើម្បីធានានូវសុវត្ថិភាពនិងសុខភាពការងារ ដោយគិតរួមទាំងកម្មវិធីបង្ការគ្រោះថ្នាក់ពេលធ្វើដំណើររបស់សមាជិក **ប.ស.ស.**។

**មាត្រា៦៨ ‑ សិទ្ធិវន្តនៃធនលាភឧត្តរជីវី**

សិទ្ធិវន្តនៃធនលាភឧត្តរជីវី រួមមាន សហព័ទ្ធនិងកូន ព្រមទាំងឪពុកម្ដាយឬមនុស្សចាស់ជរាដែលរស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនមុនពេលទទួលមរណភាព និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. សម្រាប់ប្ដីឬប្រពន្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទនៃហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារ។

២. ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖
- មិនទាន់រៀបអាពាហ៍ពិពាហ៍
- ជាកូនបង្កើត
- ក្នុងករណីមានការលែងលះឬករណីមរណភាពនៃប្ដីឬប្រពន្ធ កូននៃគូស្រករក្រោយដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍មុនដែរ
- កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ
- មានអាយុមិនលើសពី២១(ម្ភៃមួយ)ឆ្នាំ។

កូនពិការឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារឬមុខរបរដែលមានប្រាក់ចំណូល ត្រូវផ្ដល់ធនលាភឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.**។

៣. ឪពុកម្ដាយឬមនុស្សចាស់ជរានៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះដែលមានអាយុយ៉ាងតិច៦០(ហុកសិប)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទនៃការទទួលមរណភាពរបស់ជនរងគ្រោះនិងមិនមានប្រកបមុខរបរដែលមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព។ ចំពោះឪពុកម្ដាយឬមនុស្សចាស់ជរាដែលមានជំងឺរ៉ាំរ៉ៃ ព្យាបាលមិនជា ឬមានទុព្វលភាព និងមិនមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព មិនត្រូវបានកំណត់អាយុឡើយ។

៤. សិទ្ធិទទួលបានធនលាភឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖
- សាមីជនទទួលមរណភាព
- ប្ដីឬប្រពន្ធរៀបអាពាហ៍ពិពាហ៍ជាថ្មី ស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក **ប.ស.ស.** យ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ផ្នែកទី២

## ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ

### មាត្រា៦៩ _ សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ មានដូចខាងក្រោមៈ

- ការព្យាបាលនិងថែទាំមុខរបួសឬជំងឺដែលបណ្ដាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ រហូតជាសះស្បើយ ទោះអ្នករងគ្រោះសម្រាកឬមិនសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលក្ដី
- ការផ្ដល់សេវាសង្គ្រោះបន្ទាន់
- ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាលនិងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល
- ការផ្ដល់សេវាដឹកសពឬសេវាបញ្ជូនជនរងគ្រោះដែលត្រូវសង្គ្រោះបន្ទាន់
- ការផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះ ក្នុងពេលសម្រាកព្យាបាលសម្រាប់ករណីធ្ងន់ធ្ងរដែលសាមីជនរងគ្រោះមិនអាចបម្រើខ្លួនឯងបាន។

### មាត្រា៧០ _ ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន

ក្នុងរយៈពេលនៃការសម្រាកព្យាបាលមុខរបួសឬជំងឺដែលបណ្ដាលមកពីហានិភ័យការងារនៅតាមមូលដ្ឋានសុខាភិបាល និងរយៈពេលសម្រាកក្រោយការចេញពីមូលដ្ឋានសុខាភិបាល តាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យផ្លូវការឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស. ប្រាក់បៀវត្សរបស់សាមីជនរងគ្រោះត្រូវបានរក្សាទុកដដែល។

### មាត្រា៧១ _ ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈដែលទទួលរងហានិភ័យការងារបណ្ដាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងកម្រិតចាប់ពី២០%(ម្ភៃភាគរយ)ឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ បែបបទនិងនីតិវិធីស្ដីពីការគណនាធនលាភ ការកំណត់កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងការផ្ដល់ធនលាភ ត្រូវកំណត់ដោយអនុក្រឹត្យ។

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈដែលកំពុងទទួលធនលាភដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែក ប៉ុន្តែត្រូវទទួលរងហានិភ័យការងារជាថ្មី ត្រូវទទួលបានធនលាភស្របតាមកម្រិតនៃការបាត់បង់សមត្ថភាពការងារសរុប។ កម្រិតនៃការបាត់បង់សមត្ថភាពការងារសរុបត្រូវស្មើនឹងកម្រិតបាត់បង់សមត្ថភាពការងារដើមដំបូងបូកនឹងកម្រិតបាត់បង់សមត្ថភាពការងារបន្តបន្ទាប់នៃសរីរាង្គផ្សេងទៀត ប៉ុន្តែមិនត្រូវលើសពី១០០%(មួយរយភាគរយ)ឡើយ។

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាប្រាក់បណ្ដោះអាសន្នប្រចាំនិច្ច។ ប.ស.ស. ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាពនិងវាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះជាទៀងទាត់។ ក្នុងករណីពិនិត្យឃើញមានការ

ប្រែប្រួលចំពោះកម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវមានការវាយតម្លៃនិងសើរើចំនួនប្រាក់ធនលាភដែលត្រូវផ្តល់ឡើងវិញ។

ជនរងគ្រោះមិនអាចជំទាស់នឹងការពិនិត្យសុខភាពដូចកំណត់ខាងលើបានទេ។ ក្នុងករណីដែលសាមីជនមិនបានចូលខ្លួនមកពិនិត្យតាមកាលកំណត់ ប.ស.ស. អាចផ្អាកការផ្តល់ធនលាភរហូតដល់មានការបង្ហាញខ្លួនរបស់សាមីជន។

**មាត្រា៧២ .- វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈ ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងកម្រិតតិចជាង ២០% (ម្តៃភាគរយ) មានសិទ្ធិទទួលបានវិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។

វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវបានបើកផ្តល់ជូនតែម្តងគត់។

បែបបទនិងនីតិវិធីនៃការគណនាវិភាជន៍បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៣ .- វិភាជន៍បូជាសពនិងធនលាភឧត្តរជីវី**

ក្នុងករណីដែលសមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈ ដែលទទួលរងគ្រោះដោយហានិភ័យការងាររហូតដល់បាត់បង់ជីវិត ប.ស.ស. ត្រូវផ្តល់វិភាជន៍បូជាសពនិងធនលាភឧត្តរជីវី។

វិភាជន៍បូជាសពត្រូវផ្តល់ជូនសិទ្ធិវន្តដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ ឬអ្នកដែលបានចាត់ចែងបូជាសពជនរងគ្រោះដោយផ្ទាល់។ ចំនួនវិភាជន៍បូជាសពត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។

ធនលាភឧត្តរជីវីត្រូវផ្តល់ជូនសិទ្ធិវន្តដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ។ ការគណនា បែបបទនិងនីតិវិធីនៃការផ្តល់ធនលាភឧត្តរជីវីត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧៤ .- សេវាស្តារនីតិសម្បទា**

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈ ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទាដែលរួមមាន សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ឬសេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ឬសេវាសង្គម។

សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ត្រូវបានផ្តល់សម្រាប់គាំទ្រដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រឬសម្រាប់ជួយសម្រួលដល់ជនរងគ្រោះដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ត្រូវបានផ្តល់ជូនសមាជិក ប.ស.ស. ដែលធ្លាក់ខ្លួនពិការដោយហានិភ័យការងារ ដើម្បីមានឱកាសទទួលបានការងារឬមុខរបរថ្មី ស្របតាមកាយសម្បទារបស់ខ្លួន។

ជនពិការដោយហានិភ័យការងារ មានសិទ្ធិទទួលបាននូវការប្រឹក្សា ការតម្រង់ទិស ការអប់រំចិត្តសាស្ត្រ និងសេវាសង្គមនានា ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវផ្នែកចិត្តសាស្ត្រសង្គម ទទួលបានភាពម្ចាស់ការ ស្របតាមស្ថានភាពរស់នៅប្រចាំថ្ងៃ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាស្តារនីតិសម្បទាត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣
## ផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ

### មាត្រា៧៥ – សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវអនុវត្តដូចគ្នានឹងការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ សម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលមានចែងក្នុងមាត្រា៦៩នៃច្បាប់នេះ។

### មាត្រា៧៦ – ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

ក្នុងរយៈពេលនៃការសម្រាកព្យាបាលមុខរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារនៅតាមមូលដ្ឋានសុខាភិបាល និងរយៈពេលសម្រាកក្រោយការចេញពីមូលដ្ឋានសុខាភិបាល តាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យផ្លូវការឬគ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស. សាមីជនរងគ្រោះមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវគិតចាប់ពីថ្ងៃទីពីរដែលសាមីជនរងគ្រោះថ្នាក់របួតមុខរបួសឬជំងឺជាសះស្បើយ ឬទទួលមរណភាព ដោយគិតរួមទាំងរយៈពេលដែលគ្រូពេទ្យព្យាបាលអនុញ្ញាតឲ្យឈប់សម្រាកបន្ទាប់ពីចេញពីមូលដ្ឋានសុខាភិបាលផងដែរ។ ប្រាក់ឈ្នួលរបស់សាមីជនសម្រាប់ថ្ងៃផ្អាកការងារដំបូងជាបន្ទុករបស់និយោជក។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង៧០%(ចិតសិបភាគរយ)នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន ក្នុងរយៈពេល៦(ប្រាំមួយ)ខែចុងក្រោយ។ ក្នុងករណីដែលរយៈពេលបំពេញការងាររបស់សាមីជនតិចជាង៦(ប្រាំមួយ)ខែ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវគិតតាមស្ថានភាពជាក់ស្តែង។

### មាត្រា៧៧ – ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា[illegible]នៃច្បាប់នេះ។

**មាត្រា៧៨ ‑ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧២នៃច្បាប់នេះ។

**មាត្រា៧៩ ‑ វិភាជន៍បូជាសពនិងធនលាភឧត្តរជីវី**

វិភាជន៍បូជាសពនិងធនលាភឧត្តរជីវីត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧៣នៃច្បាប់នេះ។

**មាត្រា៨០ ‑ សេវាស្តារនីតិសម្បទា**

សេវាស្តារនីតិសម្បទាត្រូវអនុវត្តដូចមានបញ្ញត្តក្នុងមាត្រា៧៤នៃច្បាប់នេះ។

## ជំពូកទី៧
## របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ

**មាត្រា៨១ ‑ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកនិកម្មភាពការងារ**

បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានសិទ្ធិទទួលបានតាវកាលិកផ្នែកនិកម្មភាពការងារ។

បទប្បញ្ញត្តិនេះមិនត្រូវបានអនុវត្តចំពោះមន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទោះបីមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈក៏ដោយ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកនិកម្មភាពការងារត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨
## សហវិធាន
## ផ្នែកទី១
## វិធានប្រតិបត្តិការងារ

**មាត្រា៨២ ‑ វិធានប្រតិបត្តិការងារ**

និយោជកត្រូវមានកាតព្វកិច្ចចុះបញ្ជីសហគ្រាសគ្រឹះស្ថាន ចុះបញ្ជីកម្មករនិយោជិតក្នុង **ប.ស.ស.** និងរាយការណ៍ជាទៀងទាត់នូវចំនួនកម្មករនិយោជិត ព្រមទាំងប្រមូលភាគទានរបបសន្តិសុខសង្គម ដោយគិតទាំងផ្នែកនៃភាគទានជាបន្ទុករបស់ខ្លួនផ្ទាល់ បូករួមនឹងផ្នែកនៃភាគទានជាបន្ទុករបស់កម្មករនិយោជិតផង ដើម្បីបង់ចូលក្នុងគណនីនៃ **ប.ស.ស.** តាមកាលកំណត់។

បែបបទនៃការចូលរួមរបស់និយោជក ការចុះបញ្ជីសហគ្រាសគ្រឹះស្ថាន ការចុះបញ្ជីកម្មករនិយោជិត របាយការណ៍ចំនួនកម្មករនិយោជិត ការបង់ភាគទានដែលជាបន្ទុករបស់និយោជក បុគ្គលនៃវិស័យសាធារណៈ និងកម្មករនិយោជិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

និយោជក បុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ

ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានកាតព្វកិច្ចចូលរួមក្នុងគ្រោងរបបសន្តិសុខសង្គម តាមបទប្បញ្ញត្តិនៃច្បាប់នេះ។

បុគ្គលស្វ័យនិយោជន៍អាចចូលរួមដោយស្ម័គ្រចិត្តក្នុងផ្នែកថែទាំសុខភាពនិងផ្នែកប្រាក់សោធន។

**មាត្រា៨៣ _ ការផ្តល់ឯកសារព្យាបាលវេជ្ជសាស្ត្ររបស់មូលដ្ឋានសុខាភិបាល**

មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ត្រូវផ្តល់ឯកសារព្យាបាលវេជ្ជសាស្ត្រនៃសមាជិក ប.ស.ស. ឬឯកសារចាំបាច់ដទៃទៀតដល់ ប.ស.ស. នៅពេលមានសំណើជាផ្លូវការឬនៅពេលមានតម្រូវការចាំបាច់ ដើម្បីទុកជាទិន្នន័យសម្រាប់ការស្រាវជ្រាវ វិភាគ និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងរបស់មូលដ្ឋានសុខាភិបាល។

ឯកសារទាំងអស់ខាងលើត្រូវទុកជាការសម្ងាត់។ បុគ្គលដែលចូលរួមក្នុងការស្រាវជ្រាវវិភាគនិងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងនេះត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈនិងសិទ្ធិឯកជនរបស់បុគ្គល។

## ផ្នែកទី២

## សកម្មភាពសុខាភិបាលនិងសង្គមកិច្ច

**មាត្រា៨៤ _ សកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គម**

- ត្រូវបង្កើតឲ្យមានសកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គមដើម្បីបំពេញបន្ថែមលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

សកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គម មានប្រភពមូលនិធិមកពី៖

- ប្រាក់ពិន័យនិយោជកទាក់ទងនឹងការខកខានឬមានកំហុសក្នុងការអនុវត្តតាមច្បាប់និងបទបញ្ជាផ្សេងៗ
- ថវិកាគ្រោងសម្រាប់ធ្វើសកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គមនៃផ្នែកនីមួយៗក្នុងរបបសន្តិសុខសង្គម។

មូលនិធិសកម្មភាពពាក់ព័ន្ធនឹងផ្នែកសុខភាពនិងសង្គមត្រូវប្រើប្រាស់លើសកម្មភាពដូចខាងក្រោម៖

- ការបង្ការសុខភាពទូទៅ
- ការបង្ការហានិភ័យការងារ
- ការសិក្សា ស្រាវជ្រាវ និងធ្វើស្ថិតិសន្តិសុខសង្គម
- ការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល
- ការផ្តល់ជំនួយខាងហិរញ្ញវត្ថុឬការចូលរួមជាមួយស្ថាប័នសាធារណៈឬឯកជនក្នុងផ្នែកពាក់ព័ន្ធសុខភាពនិងសង្គមដែលមានសកម្មភាពជាប្រយោជន៍សម្រាប់សមាជិក ប.ស.ស.។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៣
## សិទ្ធិនិងអត្ថប្រយោជន៍បន្ថែម

**មាត្រា៨៥ – រយៈពេលដែលចាត់ទុកជារយៈពេលបង់ភាគទានផ្នែកប្រាក់សោធន**

រយៈពេលដែលត្រូវចាត់ទុកជាសមាជិក **ប.ស.ស.** បានបង់ភាគទានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន រួមមាន រយៈពេលបរិចារកិច្ចយោធា រយៈពេលសម្រាកព្យាបាលជំងឺតាមមូលដ្ឋានសុខាភិបាល រយៈពេលសម្រាកមាតុភាព និងរយៈពេលអាក់ខានធ្វើការដោយហានិភ័យការងារ។

**មាត្រា៨៦ – ការបើកប្រាក់ធនលាភនិងប្រាក់សោធន**

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%(ម្ភៃភាគរយ)ឡើងនិងប្រាក់សោធនទាំងអស់ត្រូវបើកផ្តល់ប្រចាំខែ។

**មាត្រា៨៧ – អាជ្ញាយុកាលនៃការទាមទារតាវកាលិក**

សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ប្រាក់វិភាជន៍បូជាសព ប្រាក់បំណាច់មាតុភាព និងប្រាក់ព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងករណីសង្គ្រោះបន្ទាន់ ត្រូវអស់សុពលភាពត្រឹមរយៈពេល១(មួយ)ឆ្នាំ។

សិទ្ធិនៃការទាមទារប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍និងធនលាភឧត្តរជីវី ត្រូវអស់សុពលភាពត្រឹមរយៈពេល៥(ប្រាំ)ឆ្នាំ។

សិទ្ធិនៃការទាមទារប្រាក់សោធនជរាភាព ទុព្វលភាព និងសោធនឧត្តរជីវីត្រូវអស់សុពលភាពត្រឹមរយៈពេល៥(ប្រាំ)ឆ្នាំ។

**មាត្រា៨៨ – សិទ្ធិទទួលបានអ្នកថែរក្សា**

សមាជិក **ប.ស.ស.** ដែលទទួលបានប្រាក់ធនលាភដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ឬទទួលបានសោធនទុព្វលភាព ដែលតម្រូវឲ្យមានអ្នកថែរក្សា មានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែរក្សាមានចំនួនស្មើនឹង៥០%(ហាសិបភាគរយ)នៃប្រាក់ធនលាភឬប្រាក់សោធនរបស់សាមីជន។

លក្ខខណ្ឌឬស្ថានភាពដែលតម្រូវឲ្យមានអ្នកថែរក្សាត្រូវសម្រេចដោយក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.**។

**មាត្រា៨៩ – ភាពមិនអាចរឹបអូសឬផ្ទេរបាននៃតាវកាលិក**

តាវកាលិកនៃរបបសន្តិសុខសង្គមទាំងអស់មិនអាចផ្ទេរឬរឹបអូសបានទេ លើកលែងតែមានការយល់ព្រមពីអត្តគាហកផ្ទាល់។

**មាត្រា៩០ – ភាពត្រួតគ្នានៃតាវកាលិក**

[illegible]ដែលមានតាវកាលិកត្រួតគ្នា ទោះជាតាវកាលិកផ្នែកប្រាក់សោធនជាកាតព្វកិច្ច [illegible]ក្តី អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ សាមីជនមានសិទ្ធិទទួលបានប្រាក់សោធន [illegible]ដែលមានចំនួនទឹកប្រាក់ខ្ពស់ជាង។

## ផ្នែកទី៤
## ការដោះស្រាយវិវាទ

### មាត្រា៦១ .. ការដោះស្រាយវិវាទ

វិវាទឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមរវាងសមាជិក ប.ស.ស. និយោជក និង ប.ស.ស. ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស.។ ក្នុងករណីមិនមានការសះជាវិវាទឬបណ្តឹងនោះអាចត្រូវបានប្តឹងទៅនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការងារ មុននឹងប្តឹងទៅសាលាដំបូងនៃរាជធានី ខេត្ត ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ។

## ផ្នែកទី៥
## យន្តការសម្របសម្រួល

### មាត្រា៦២ .. ការបង្កើតយន្តការសម្របសម្រួល

ត្រូវបង្កើតឲ្យមានយន្តការសម្របសម្រួលរវាងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ បុគ្គលស្វ័យនិយោជន៍ និងបុគ្គលទាំងឡាយណាដែលមិនស្ថិតក្រោមវិសាលភាពនៃច្បាប់នេះ។

ប.ស.ស. អាចចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នសន្តិសុខសង្គមនៃប្រទេសទទួលពលករដើម្បីបង្កើតយន្តការគាំពារផ្នែកសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតទេសន្តរប្រវេសក៍និងតាមបែបបទនិងនីតិវិធីជាធរមាន។

បែបបទនៃការអនុវត្តយន្តការសម្របសម្រួលខាងលើត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៦
## បុព្វសិទ្ធិលើទ្រព្យសម្បត្តិនិងការគ្រប់គ្រងហិរញ្ញវត្ថុ

### មាត្រា៦៣ .. ភាពមិនជាប់ភាគព្វកិច្ចពន្ធអាករ

ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ប.ស.ស. ត្រូវរួចផុតពីការបង់ពន្ធនិងអាករគ្រប់ប្រភេទ។ ក្នុងករណីប្រតិបត្តិការរបស់បេឡានេះដែលមានចរិតជាពាណិជ្ជកម្មឬមានគោលដៅរកផលចំណេញ ត្រូវជាប់ពន្ធអាករតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

### មាត្រា៦៤ .. បុព្វសិទ្ធិនៃការប្រមូលភាគទាន បំណុល និងទ្រព្យសម្បត្តិ

ប.ស.ស. មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលភាគទានការឲ្យសងបំណុល និងការរឹបអូសទ្រព្យសម្បត្តិ។

ប.ស.ស. មានឯកសិទ្ធិលើទ្រព្យទាំងអស់របស់កូនបំណុលក្នុងលំដាប់បន្ទាប់ពីសិទ្ធិលើប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

នីតិវិធីនៃការអនុវត្តបុព្វសិទ្ធិនិងការទារបំណុលរបស់ ប.ស.ស. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៥ _ ការគ្រប់គ្រងនិងថែរក្សាមូលនិធិសន្តិសុខសង្គម**

មូលនិធិសន្តិសុខសង្គមត្រូវរក្សាទុកនៅធនាគារនានាដែលស្របច្បាប់ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. ដោយមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មូលនិធិសន្តិសុខសង្គមត្រូវដាក់ក្នុងគណនីធនាគារផ្សេងៗគ្នាតាមផ្នែកនិងវិស័យនីមួយៗ។

ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. អាចប្រើប្រាស់មូលនិធិសល់ពីប្រាក់ត្រៀមបម្រុងនៃផ្នែកនីមួយៗសម្រាប់ការវិនិយោគ ដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម ដើម្បីស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៧

## យន្តការត្រួតពិនិត្យការអនុវត្តការងារនៃ ប.ស.ស.

**មាត្រា៦៦ _ ការត្រួតពិនិត្យនិងសវនកម្មលើឡាជាតិសន្តិសុខសង្គម**

ប.ស.ស. ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនិងធ្វើសវនកម្មដោយអាជ្ញាធរសវនកម្មជាតិ។ ក្នុងករណីចាំបាច់ និយ័តករសន្តិសុខសង្គមឬក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. អាចស្នើឲ្យមានការធ្វើសវនកម្មពីស្ថាប័នសវនកម្មឯករាជ្យណាមួយ។

# ជំពូកទី៩

# ទោសប្បញ្ញត្តិ

**មាត្រា៦៧ _ ទណ្ឌកម្មរដ្ឋបាលនិងទោសប្បញ្ញត្តិ**

ទណ្ឌកម្មក្នុងជំពូកនេះរួមមាន ការពិន័យអន្តរការណ៍ ការពិន័យជាប្រាក់ ឬការផ្តន្ទាទោសដាក់ពន្ធនាគារ។

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អគ្គនាយក ប.ស.ស.។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងបទល្មើសត្រូវបញ្ជូនទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។

បែបបទនិងនីតិវិធីក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។

**មាត្រា៦៨ _ ការមិនអនុវត្តកាតព្វកិច្ចបង់ភាគទាន**

[illegible]សហគ្រាស គ្រឹះស្ថានដែលមិនអនុវត្តកាតព្វកិច្ចនៃការបង់ភាគទានតាមកាលកំណត់ ឬមិនអនុវត្តកាតព្វកិច្ចរាយការណ៍ពីកម្មករនិយោជិតឲ្យបានត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា៤២នៃច្បាប់នេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ពី១០(ដប់)ដងទៅ៣០(សាមសិប)ដង

នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ការពិន័យនេះត្រូវអនុវត្តស្មើនឹងចំនួនមនុស្សដែលនិយោជក បានប្រើប្រាស់ក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៩៩ _ ការដកយកភាគទានមិនអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់**

និយោជកដែលបានដកយកភាគទានផ្នែកហានិភ័យការងារពីប្រាក់ឈ្នួលកម្មករនិយោជិត ឬបានដកយកភាគទានដែលជាបន្ទុករបស់ខ្លួនដោយការកាត់យកពីប្រាក់ឈ្នួលកម្មករនិយោជិត សម្រាប់បង់ភាគទានផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន ឬផ្នែកនិកម្មភាពការងារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែដល់១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១២០(មួយរយម្ភៃ)ដងទៅ៣៦០(បីរយហុកសិប)ដងនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ការពិន័យនេះត្រូវអនុវត្តស្មើនឹងចំនួនមនុស្សដែលនិយោជកបានដកយកប្រាក់ភាគទានក្នុងលក្ខខណ្ឌដែលផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០០ _ បទប្រឆាំងនឹងអធិការកិច្ចសន្តិសុខសង្គម**

ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៥០៣(បទប្រឆាំងនឹងអ្នករាជការសាធារណៈ)នៃក្រមព្រហ្មទណ្ឌ ចំពោះអំពើប្រឆាំងនឹងការអនុវត្តមុខងាររបស់អធិការកិច្ចសន្តិសុខសង្គមដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់។

**មាត្រា១០១ _ បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ**

ត្រូវផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា៣១៤(បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ)នៃក្រមព្រហ្មទណ្ឌ ចំពោះអធិការសន្តិសុខសង្គមឬមន្ត្រីសាធារណៈដែលបានបើកកកាយការសម្ងាត់អំពីរបៀបផលិតឬការសម្ងាត់នៃឯកសារវេជ្ជសាស្ត្រ។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

### ផ្នែកទី១

### ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច សម្រាប់បុគ្គលនៃវិស័យសាធារណៈ

**មាត្រា១០២ _ ការចូលនិវត្តន៍មុនអាយុចូលនិវត្តន៍**

សមាជិក ប.ស.ស. ជាបុគ្គលនៃវិស័យសាធារណៈ ដែលបានបម្រើការងារអស់រយៈពេលយ៉ាងតិច៣០(សាមសិប)ឆ្នាំ មានសិទ្ធិស្នើសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍៦០(ហុកសិប)ឆ្នាំ ដោយទទួលបានប្រាក់សោធនដែលត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

សិទ្ធិស្នើសុំចូលនិវត្តន៍មុនអាយុចូលនិវត្តន៍ មានសុពលភាពអនុវត្តក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីព្រះរាជក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ចូលជាធរមាន។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

## ផ្នែកទី២
## សោធនជរាភាពអយ្យកប្បញ្ញត្តិ

### មាត្រា១០៣ .- សោធនជរាភាពអយ្យកប្បញ្ញត្តិ

សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានអាយុលើសពី៣០(សាមសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការដំបូងនៃផ្នែកប្រាក់សោធន មានសិទ្ធិទទួលបានសោធនជរាភាពអយ្យកប្បញ្ញត្តិ។ សោធនជរាភាពអយ្យកប្បញ្ញត្តិត្រូវបានផ្តល់ លុះត្រាតែសាមីជនបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច២៤(ម្ភៃបួន)ខែ ក្នុងរយៈពេល៣៦(សាមសិបប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមដំណើរការផ្នែកប្រាក់សោធន។

## ផ្នែកទី៣
## ផ្នែកសន្តិសុខសង្គមកំពុងដំណើរការ

### មាត្រា១០៤ .- ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកសោធននិវត្តន៍កំពុងដំណើរការ

រដ្ឋនិងនិយោជកត្រូវបន្តបង់ភាគទានទាំងស្រុងសម្រាប់ផ្នែកថែទាំសុខភាពរហូតដល់មានការកំណត់ជាថ្មី។

រាល់លិខិតបទដ្ឋានគតិយុត្តដែលកំពុងអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវទុកឲ្យអនុវត្តបន្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីដែលអនុលោមតាមច្បាប់នេះមកជំនួស។

ការផ្តល់សេវាថែទាំសុខភាពតាមរយៈមូលនិធិសមធម៌សុខាភិបាលត្រូវទុកឲ្យអនុវត្តបន្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។ ប្រភពធនធានសម្រាប់ផ្នែកនេះជាបន្ទុករបស់រដ្ឋ។

រាល់លិខិតបទដ្ឋានគតិយុត្តដែលកំពុងអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវទុកឲ្យអនុវត្តបន្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីដែលអនុលោមតាមច្បាប់នេះមកជំនួស។

## ផ្នែកទី៤
## ការរួមបញ្ចូលរចនាសម្ព័ន្ធគ្រប់គ្រង

### មាត្រា១០៥ .- ការរួមបញ្ចូលរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកប្រាក់សោធន

ការរួមបញ្ចូលរចនាសម្ព័ន្ធគ្រប់គ្រងផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលជាមន្ត្រីបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនទៅក្នុង ប.ស.ស. ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា១០៦.- ការទុកជានិរាករណ៍**

ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០៧.- ការប្រកាសជាការប្រញាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ៦កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

ចាវស.១៩១១.១៦៥៥

នសីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម

## និយមន័យនៃពាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម

### ក

| | |
|---|---|
| ១. កម្មករនិយោជិតទេសន្តរប្រវេសក៍ | សំដៅដល់ជនគ្រប់ភេទដែលចាកចេញទៅធ្វើការនៅក្រៅប្រទេស ដោយស្របច្បាប់និងបានចុះបញ្ជីក្នុងស្ថាប័នសន្តិសុខសង្គមនៃប្រទេសទទួលឲ្យធ្វើការ។ |
| ២. កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ | សំដៅដល់ជនគ្រប់ភេទនិងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកប្រាក់ឈ្នួលក្រោមការដឹកនាំនិងគ្រប់គ្រងរបស់និយោជកម្នាក់ឬច្រើននាក់ ដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ប្រភេទ ទម្រង់ និងសុពលភាពនៃកិច្ចសន្យាការងារ ឬប្រភេទ និងចំនួនប្រាក់ឈ្នួល។ កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធត្រូវគិតរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះផងដែរ។ |
| ៣. កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ | សំដៅដល់ជនគ្រប់ភេទដែលធ្វើការងារសេរី យកថ្លៃឈ្នួលភ្លាមៗ តាមសាច់ការឬទំហំការងារ ឬតាមការតថ្លៃជាក់ស្តែង ដោយភាគីដែលផ្តល់ថ្លៃឈ្នួលមិនមានកាតព្វកិច្ចទទួលខុសត្រូវដូចនិយោជកឡើយ។ |
| ៤. ការងារឬមុខរបរដែលមានប្រាក់ចំណូល | សំដៅដល់គ្រប់ប្រភេទការងារឬមុខរបរទាំងអស់ដែលអាចទទួលបាននូវកម្រៃ ទោះជាវត្ថុឬជាប្រាក់ក្តីដែលមានចំនួនលើសពីចំណូលដែលកំណត់ខ្សែបន្ទាត់ក្រីក្រ។ |
| ៥. ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន | សំដៅដល់ការអាក់ខាន មិនអាចធ្វើការងារក្នុងរយៈពេលនៃការសម្រាកព្យាបាលជំងឺ ឬមុខរបួសដែលបណ្តាលមកពីហានិភ័យការងារ ដោយគិតរួមទាំងការសម្រាកក្រោយការព្យាបាលតាមវេជ្ជបញ្ជានៃគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ដោយ ប.ស.ស.។ |
| ៦. ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ | សំដៅដល់ការមិនអាចធ្វើការងារទាំងស្រុងឬដោយផ្នែក ដោយការបាត់បង់សរីរាង្គឬអវយវៈណាមួយដែលបណ្តាលមកពីហានិភ័យការងារ។ ការបាត់បង់ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សមត្ថភាពការងារអចិន្ត្រៃយ៍ មានពីរប្រភេទ គឺការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែកឬទាំងស្រុង។

| | |
|---|---|
| ៧. កូនជាងឬសិស្សវិជ្ជាជីវៈ | សំដៅដល់ជនគ្រប់ភេទដែលបានចុះកិច្ចសន្យាក្នុងឋានៈជាកូនជាងឬសិស្សវិជ្ជាជីវៈ ដើម្បីទទួលបានការអប់រំវិជ្ជាជីវៈពេញលេញនិងតាមរបៀបបច្ចេកទេសនៅតាមសហគ្រាស គ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្ម ឬក៏ជាមួយសិប្បករឬមេជាងម្នាក់។ |
| ៨. ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម | សំដៅដល់ក្រុមប្រឹក្សាដែលមានភារកិច្ចរក្សានិងគ្រប់គ្រងទ្រព្យសម្បត្តិនៃ ប.ស.ស. ក្នុងនាមក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.។ |
| ៩. ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម | សំដៅដល់ក្រុមប្រឹក្សាដែលមានភារកិច្ចម្យ៉ាងក្នុងការផ្តល់ដំបូន្មានលើកិច្ចការត្រួតពិនិត្យគុណភាពនិងថ្លៃសេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. និងការវាយតម្លៃកំណត់អត្រានៃការបាត់បង់សមត្ថភាពការងារ ឬអត្រាទុព្វលភាព ឬប្រភេទជំងឺវិជ្ជាជីវៈ។ |

**គ**

| | |
|---|---|
| ១០. គ្រូពេទ្យផ្លូវការ | សំដៅដល់គ្រូពេទ្យដែលបម្រើការនៅមូលដ្ឋានសុខាភិបាលសាធារណៈឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលដែល ប.ស.ស. ពិនិត្យទទួលស្គាល់សម្រាប់ផ្នែកហានិភ័យការងារ។ |
| ១១. គ្រូពេទ្យទទួលស្គាល់ដោយ ប.ស.ស. | សំដៅដល់គ្រូពេទ្យឯកទេសដែលអគ្គនាយក ប.ស.ស. ប្រគល់សិទ្ធិសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃផ្នែកវេជ្ជសាស្ត្រសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងផ្នែកហានិភ័យការងារ។ |
| ១២. គ្រោះថ្នាក់ការងារ | សំដៅដល់គ្រោះថ្នាក់ដែលកើតឡើងដោយចៃដន្យនិងភ្លាមៗក្នុងពេលធ្វើការងារ ដោយធ្វើការងារឬនៅកន្លែងធ្វើការងារ ដោយមូលហេតុទាក់ទងនឹងកំហុសជនរង |

គ្រោះឬគ្មានកំហុសក៏ដោយ ដែលបណ្តាលឲ្យជនរងគ្រោះទទួលរងរបួសស្នាមជាយថាហេតុ។ គ្រោះថ្នាក់ការងារត្រូវចាត់ទុកជាហានិភ័យការងារ។

១៣. គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ

សំដៅដល់គ្រោះថ្នាក់កើតឡើងពេលធ្វើដំណើរនៅលើកំណាត់ផ្លូវត្រង់រវាងលំនៅឋាននិងកន្លែងធ្វើការងារក្នុងថិរវេលាសមស្រប។ អធិការសន្តិសុខសង្គមមានឆន្ទានុសិទ្ធិក្នុងការចាត់ទុកគ្រោះថ្នាក់ពេលធ្វើដំណើរជាហានិភ័យការងារ ដោយផ្អែកលើហេតុផលជាក់ស្តែងដែលទទួលបានពីការអង្កេតលើករណីគ្រោះថ្នាក់នីមួយៗ។

១៤. គ្រោះថ្នាក់បង្កឡើងដោយចេតនា

សំដៅដល់គ្រោះថ្នាក់ដែលកើតឡើងដោយការគ្រោងទុកបង្កឡើងដោយចេតនារបស់បុគ្គល ក្នុងបំណងទទួលបានប្រយោជន៍ជាតាវកាលិកពី **ប.ស.ស.** ឬក្នុងគោលបំណងស្វែងរកប្រយោជន៍ណាមួយផ្សេងទៀត។

## ឆ

១៥. ឆ្នាំភាគទាន

សំដៅដល់ចំនួនឆ្នាំដែលសមាជិក **ប.ស.ស.** បានបង់ភាគទានក្នុងផ្នែកប្រាក់សោធន។ ឆ្នាំភាគទានត្រូវបានគណនាដោយយកចំនួនខែដែលសាមីជនបានបង់ភាគទានផ្នែកប្រាក់សោធនចែកនឹង១២(ដប់ពីរ)។ ផលចែកនៃឆ្នាំភាគទានត្រូវបង្កើន បើសំណល់លើសពី៦(ប្រាំមួយ)ខែ ឬត្រូវបន្ថយ បើសំណល់ត្រឹម៦(ប្រាំមួយ)ខែចុះ។ ឧទាហរណ៍ បើគណនាឃើញ២៥ឆ្នាំ៧ខែ ឆ្នាំភាគទានត្រូវស្មើ២៦ឬបើ២៥ឆ្នាំ៦ខែ នោះឆ្នាំភាគទានស្មើ២៥។

## ជ

១៦. ជំងឺវិជ្ជាជីវៈ

សំដៅដល់សភាពនៃរោគសមុដ្ឋានឬការកើតរោគដែលពាក់ព័ន្ធនឹងការអនុវត្តការងារក្នុងមុខរបរណាមួយជាកំណត់ ពោលគឺរោគឬជំងឺដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកត្តានានានៃការងារមានជាអាទិ៍ កំលុងពេលធ្វើការងារ កន្លែងធ្វើការងារ របៀបធ្វើការងារ សារធាតុឬវត្ថុធាតុប្រើប្រាស់ក្នុងផលិតកម្ម បរិយាកាសនៃកន្លែងធ្វើការ ជាដើម ដែលអាចធ្វើឲ្យកើតរោគឬជំងឺ

ទោះបីក្នុងកំលុងពេលដែលសាមីជនកំពុងបំពេញការងារ ឬមុខរបរ ឬក្រោយកំលុងពេលដែលលែងបំពេញការងារ ឬមុខរបរទាំងនោះក្តី។ ជំងឺវិជ្ជាជីវៈត្រូវចាត់ទុកជាហានិភ័យការងារ។ ជំងឺទូទៅ ទោះបីកើតនៅកន្លែងធ្វើការក៏ដោយក៏មិនត្រូវបានចាត់ទុកជាហានិភ័យការងារទេ។

**១៧. តាវកាលិកនៃរបបសន្តិសុខសង្គម**

សំដៅដល់អត្ថប្រយោជន៍ក្នុងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដែលត្រូវផ្តល់ជូនដល់សមាជិក **ប.ស.ស.** នៅពេលសាមីជនជួបប្រទះនូវហានិភ័យជាយថាហេតុបណ្តាលឲ្យបាត់បង់លទ្ធភាពបំពេញការងារដើម្បីទទួលបានប្រាក់ចំណូល។ តាវកាលិកអាចជាវត្ថុឬជាប្រាក់ដែលត្រូវផ្តល់ឲ្យតាមលក្ខខណ្ឌដែលចែងក្នុងច្បាប់ឬបទប្បញ្ញត្តិពាក់ព័ន្ធ។

ឧទាហរណ៍ តាវកាលិកផ្នែកហានិភ័យការងារ មានការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។ល។

**១៨. ទុព្វលភាព**

សំដៅដល់ការបាត់បង់សមត្ថភាពការងារ ដែលមិនបណ្តាលមកពីហានិភ័យការងារ។ អាចត្រូវចាត់ទុកជាជនដែលទទួលរងទុព្វលភាព លុះត្រាតែសាមីជនជាសមាជិក **ប.ស.ស.** មានជំងឺឬរងភាពពិការនាំឲ្យអស់សមត្ថភាពរកប្រាក់ចំណូលឬរកបានប្រាក់ចំណូលទាបជាងចំណូលដែលកំណត់ក្នុងខ្សែបន្ទាត់ក្រីក្ររបស់ព្រះរាជាណាចក្រកម្ពុជា។

**១៩. ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវបើកផ្តល់ជូនសមាជិក **ប.ស.ស.** ដែលបានជួបប្រទះហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្នុងកម្រិតចាប់ពី២០%(ម្ភៃភាគរយ)ឡើង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២០. ធនលាភឧត្តរជីវី

សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវបើកផ្តល់ដល់សិទ្ធិវន្តជាឧត្តរជីវីរបស់សមាជិក ប.ស.ស. ដែលទទួលរងហានិភ័យការងាររហូតបាត់បង់ជីវិត។

## ន

២១. និកម្មភាពការងារ

សំដៅដល់វេលាដែលបុគ្គលជាសមាជិក ប.ស.ស. មិនមានសកម្មភាពការងារដែលមានប្រាក់ចំណូលឬទំនេរពីការងារដោយសារការបញ្ចប់កិច្ចសន្យាការងារ ហើយសាមីជនបានស្វះស្វែងរកការងារក្នុងរយៈពេលមួយស្របតាមការកំណត់នៃច្បាប់ឬបទប្បញ្ញត្តិបន្ទាប់ពីនិកម្មភាព។

២២. និយោជក

សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលសាធារណៈឬឯកជនដែលដឹកនាំ គ្រប់គ្រង និងប្រើកម្មករនិយោជិតម្នាក់ឬច្រើននាក់ ទោះជាមិនជាប់លាប់ក្តីដោយមានផ្តល់ប្រាក់កម្រៃជាទៀងទាត់។ តាមច្បាប់នេះ ម្ចាស់ផ្ទះដែលប្រើអ្នកបម្រើក្នុងផ្ទះក៏ត្រូវចាត់ទុកជានិយោជកដែរ។

## ប

២៣. បុគ្គលស្វ័យនិយោជន៍

សំដៅដល់ជនដែលប្រកបការងារឬមុខរបររកចំណូលផ្ទាល់ខ្លួន ដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួលឬប្រាក់បៀវត្សដែលផ្តល់ដោយនិយោជកឬរដ្ឋតាមកិច្ចសន្យាការងារ ហើយក៏មិនមានប្រើប្រាស់កម្មករនិយោជិតនៅក្នុងសកម្មភាពការងារឬមុខរបររបស់ខ្លួន។

២៤. ប្រធានសក្តិ

សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅពីឆន្ទៈ និងមិនអាចជម្នះបានដែលធ្វើឲ្យបុគ្គលមិនអាចអនុវត្តកាតព្វកិច្ចតាមច្បាប់។

២៥. ប្រព័ន្ធហិរញ្ញប្បទានពេញលេញ

សំដៅដល់ប្រព័ន្ធហិរញ្ញប្បទាន តាមបែបនៃការកំណត់ភាគទានជាគោល។ តាមប្រព័ន្ធនេះ តាវកាលិក ផ្នែកប្រាក់សោធនជាអថេរ ដោយអនុលោមតាមអត្រាភាគទាន។ ប្រាក់ភាគទាន ព្រម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | |
|---|---|
| | ទាំងផលនៃការវិនិយោគរបស់សមាជិកម្នាក់ៗត្រូវដាក់ក្នុងគណនីរបស់សាមីខ្លួន និងត្រូវផ្ដល់តាវកាលិកតាមចំនួនទឹកប្រាក់របស់សាមីខ្លួន។ |
| ២៦. ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទាន | សំដៅដល់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតឬប្រាក់បៀវត្សរបស់មន្ត្រីសាធារណៈដែលតម្រូវឲ្យជាប់ភាគទានតាមច្បាប់។ |

## ភ

| | |
|---|---|
| ២៧. ភាគទាន | សំដៅដល់ប្រាក់ដែលសមាជិក ប.ស.ស. និយោជក ឬរដ្ឋបានបង់មក ប.ស.ស. ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដែលជាទូទៅគិតជាភាគរយនៃប្រាក់ឈ្នួលឬប្រាក់បៀវត្សរបស់សមាជិកម្នាក់ៗទុកសម្រាប់ការចំណាយក្នុងការផ្ដល់តាវកាលិកដល់សមាជិក និងការចំណាយប្រតិបត្តិការនៃរបបសន្តិសុខសង្គមតាមផ្នែកនីមួយៗ។ |

## យ

| | |
|---|---|
| ២៨. យន្តការទូទាត់ថ្លៃតាមករណី | សំដៅដល់របៀបទូទាត់ថ្លៃសេវាមូលដ្ឋានសុខាភិបាលគិតតាមថ្លៃនៃករណីនីមួយៗ។ |
| ២៩. យន្តការទូទាត់ថ្លៃតាមសេវា | សំដៅដល់របៀបទូទាត់ថ្លៃសេវាមូលដ្ឋានសុខាភិបាលគិតតាមថ្លៃនៃសេវានីមួយៗ។ |

## វ

| | |
|---|---|
| ៣០. វិជ្ជាជីវៈសេរី | សំដៅដល់មុខរបរឬការងារដែលមានលក្ខណៈជាការប្រើសមត្ថភាពចំណេះដឹងខាងខួរក្បាលឬបញ្ញាជាងការប្រើកម្លាំងកាយ។ |
| ៣១. [illegible]ឬពលាភជណ្ដើរ | សំដៅដល់វិធីកំណត់កំណើនអត្រាភាគទានផ្នែកប្រាក់សោធនក្នុងរយៈពេលជាកំណត់មួយ។ |

| | |
|---|---|
| ៣២. វិភាជន៍បូជាសព | សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិក **ប.ស.ស.** ដែលទទួលមរណភាព។ |

## ស

| | |
|---|---|
| ៣៣. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | សំដៅដល់សន្ទស្សន៍ប្រែប្រួលនៃថ្លៃទំនិញប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ |
| ៣៤. សមាជិក **ប.ស.ស.** | សំដៅដល់រូបវន្តបុគ្គលដែលទទួលបានភាពជាសមាជិកនៃបេឡាជាតិសន្តិសុខសង្គម ដោយការចុះបញ្ជីនិងបានឬត្រូវបានបង់ភាគទានក្នុងផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដែលមានកំណត់ក្នុងច្បាប់នេះ។ |
| ៣៥. សេវាពិគ្រោះជំងឺក្រៅ | សំដៅដល់ការផ្តល់សេវាព្យាបាលវេជ្ជសាស្ត្រដោយមិនមានការសម្រាកនៅក្នុងមូលដ្ឋានសុខាភិបាល។ រយៈពេលដែលចាត់ទុកជារយៈពេលផ្តល់សេវាពិគ្រោះជំងឺក្រៅត្រូវមានរយៈពេលក្រោម១២(ដប់ពីរ)ម៉ោង។ |
| ៣៦. សេវាព្យាបាលដោយសម្រាកក្នុងមូលដ្ឋានសុខាភិបាល | សំដៅដល់ការផ្តល់សេវាព្យាបាលវេជ្ជសាស្ត្រដោយសម្រាកនៅក្នុងមូលដ្ឋានសុខាភិបាលចាប់ពី១២(ដប់ពីរ)ម៉ោងឡើង។ |
| ៣៧. សេវាសង្គ្រោះបន្ទាន់ | សំដៅដល់អន្តរាគមន៍ទាំងឡាយដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុកនិងត្រូវធ្វើជាបន្ទាន់ក្នុងគោលបំណងសង្គ្រោះជីវិតឬជួយការពារការបាត់បង់អវយវៈឬសរីរាង្គណាមួយរបស់ជនរងគ្រោះឬអ្នកជំងឺ។ |
| ៣៨. សេវាសម្រាលកូន | សំដៅដល់ការផ្តល់សេវាសម្រាលកូនចំពោះសមាជិក **ប.ស.ស.** ដែលជាស្ត្រី។ សេវានេះត្រូវបានគិតរួមទាំងសេវាពិនិត្យព្យាបាលមុននិងក្រោយការសម្រាលផងដែរ។ |

៣៩. សេវាស្តារនីតិសម្បទា

សំដៅដល់ការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ការផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ និងការផ្តល់សេវាសង្គម ក្នុងគោលបំណងជួយដល់ជនពិការឲ្យអាចរក្សា ស្តារ ឬធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញនិងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ ដែលបានបាត់បង់ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

៤០. សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ

សំដៅដល់ការផ្តល់ ការជួសជុល ឬការផ្តល់ជាថ្មីនូវអវយវៈសិប្បនិម្មិត រណប ឬឧបករណ៍ជំនួយការហ្វឹកហាត់កាយសម្បទាឡើងវិញ ការព្យាបាលដោយចលនា និងការផ្តល់សេវាវេជ្ជសាស្ត្រដទៃទៀត។

៤១. សោធនជរាភាពអយ្យកប្បញ្ញត្តិ

សំដៅដល់បទប្បញ្ញត្តិដើម្បីផ្តល់បុព្វសិទ្ធិពិសេសចំពោះក្រុមបុគ្គល ក្នុងពេលដែលសាមីជនត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធសោធនតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

៤២. សោធនឧត្តរជីវី

សំដៅដល់ប្រាក់សោធនដែលត្រូវផ្តល់ជូនបុគ្គលនៅក្នុងបន្ទុកផ្ទាល់នៃសោធនិកជរាភាពឬទុព្វលភាព ឬសមាជិក ម.ស.ស. ដែលបានបង់ភាគទានផ្នែកប្រាក់សោធនយ៉ាងតិច៥(ប្រាំ)ឆ្នាំ ទទួលមរណភាព។

## ហ

៤៣. ហានិភ័យការងារ

សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើង ដោយឥតគ្រោងទុកបណ្តាលមកពីគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ។

## អ

៤៤. អច្ច័យទាន

សំដៅដល់អំណោយជាបណ្តាំមរតកដែលផ្តល់ឲ្យ ម.ស.ស. ក្រៅពីទាយាទរបស់អ្នកស្លាប់ ដើម្បីជាប្រយោជន៍សាធារណៈ។

[illegible]គាហក

សំដៅដល់បុគ្គលដែលមានសិទ្ធិទទួលតាវកាលិកសន្តិសុខសង្គមតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| ៤៦. អត្រាសមាច័យ | សំដៅដល់អត្រាបង្គរនៃប្រាក់សោធនជរាភាពឬ ទុព្វលភាពក្នុងឆ្នាំភាគទាននីមួយៗរបស់សមាជិក **ប.ស.ស.**។ |

**ឧ**

| | |
|---|---|
| ៤៧. ឧត្តរជីវី | សំដៅដល់បុគ្គលដែលនៅរស់ក្នុងបន្ទុកផ្ទាល់នៃ សមាជិក **ប.ស.ស.** មុនកាលបរិច្ឆេទដែលសាមីជន បានទទួលមរណភាព ស្របតាមលក្ខខណ្ឌដែល បានកំណត់នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខៈ ៧៦១៧
មកដល់ថ្ងៃទី ២១ ខែ ១១ ឆ្នាំ ១៩
ម៉ោង ៩:០៩

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# សំណង់

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ច្បាប់នេះមានគោលបំណងធានាៈ

- គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- សោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ
- គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២ ..**

ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ..**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភេទសំណង់ដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ ..**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ ..**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣

## គោលការណ៍

**មាត្រា៦ ..**

រាល់ការងារសំណង់ត្រូវគោរពគោលការណ៍ៈ

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤
## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ ._**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ ._**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្រាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ ._**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ ._**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ឧស្សាហកម្ម តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀតដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដាកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១ ..**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាននិងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥

## ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

**មាត្រា១២ ..**

រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈនីមួយៗពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១៣ ..**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤ ..**

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

**មាត្រា១៥ ..**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលអាចប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យបាន ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ។

នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

**មាត្រា១៦ ..**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញឬបានទទួលការប្រកាសការចាប់ផ្តើបអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៧ ..**

ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្តទៅតាមប្រភេទអាជីវកម្ម។

**មាត្រា១៨ ..**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៩ .-**

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។

កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង សំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈឬអ្នកប្រកបអាជីវកម្មនិងអតិថិជនរបស់ខ្លួន។

ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ ..**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតឱ្យប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១ ..**

ការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

## ជំពូកទី៧
## ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់

**មាត្រា២២ ..**

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដាកម្ពុជានិងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដាកម្ពុជា។

បែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពនិងប្រភេទនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ ..**

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដាកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ ..**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥ ..**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦ ..**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧ ..**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ ..**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ ..**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូលឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាតត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ ..**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ ..**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

# ជំពូកទី៩

## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ ..**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ ..**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ ..**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ ..**

ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០

## ការគ្រប់គ្រងការងារសាងសង់ឬរុះរើ

**មាត្រា៣៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬរុះរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬរុះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា៣៧ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

**មាត្រា៣៨ .-**

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩ .-**

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់ [illegible] ខ្លួន។

**មាត្រា៤០ ..**

ម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់និងមានការឯកភាពពីម្ចាស់សំណង់។

បែបបទនិងនីតិវិធីនៃការផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤១ ..**

នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើត្រូវធ្វើរបាយការណ៍និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចនិងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

**មាត្រា៤២ ..**

ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ឬរុះរើ។

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

**មាត្រា៤៣ ..**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារសាងសង់ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១

## ការប្រើប្រាស់សំណង់

**មាត្រា៤៤ ..**

ការប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ROYAUME DU CAMBODGE

ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់នោះ។

រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

**មាត្រា៤៥ ._**

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្តោះអាសន្នបាន ចំពោះសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា៤៦ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧ ._**

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់ក្នុងរយៈពេលរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២(ពីរ)ឆ្នាំម្តង។

បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្តង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យធ្វើការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

មាត្រា៤៨ .-

អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ក្នុងករណីមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈ។

មាត្រា៤៩ .-

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

ចំពោះអគារសហកម្មសិទ្ធិ ម្ចាស់នៃចំណែកឯកជនទាំងអស់ត្រូវទទួលបន្ទុករួមគ្នាលើរាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ស្របតាមសមាមាត្រទៅនឹងទំហំនៃចំណែកឯកជន។

មាត្រា៥០ .-

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី១២

## សំណង់ដែលមានសភាពគ្រោះថ្នាក់

មាត្រា៥១ .-

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

មាត្រា៥២ .-

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងតម្រូវឱ្យរុះរើសំណង់។

រាល់ការចំណាយក្នុងការបញ្ចៀសគ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់។

មាត្រា៥៣ .-

[illegible]សភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់[illegible]គ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១៣

## សំណង់ដែលសាងសង់ឬកែប្រែដោយគ្មានឬខុសពីលិខិតអនុញ្ញាត

**មាត្រា៥៤ ..**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ឬកែប្រែដែលគ្មានលិខិតអនុញ្ញាត ក្នុងករណីការសាងសង់ឬកែប្រែនោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

**មាត្រា៥៥ ..**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ឬកែប្រែដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឱ្យម្ចាស់សំណង់កែតម្រូវឱ្យស្របតាមលិខិតអនុញ្ញាត។

**មាត្រា៥៦ ..**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួលឬកែប្រែរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

## ជំពូកទី១៤

## អធិការកិច្ចសំណង់

**មាត្រា៥៧ ..**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥៨ ..**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសំណង់ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៩ ..**

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ ..**

មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៦១ ..**

រាល់ប្រតិបត្តិការអធិការកិច្ចសំណង់ក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែងឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី១៥

## វិសមិតភាព

**មាត្រា៦២ ..**

មន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យនិង/ឬសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សាឬត្រួតពិនិត្យនិងបញ្ជាក់បានឡើយ។

**មាត្រា៦៣ ..**

មន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនអាចជាម្ចាស់សំណង់ ស្វាមីភរិយា ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣(បី)ថ្នាក់ ឬញាតិពន្ធក្នុង៣(បី)ថ្នាក់របស់ម្ចាស់សំណង់ ឬជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។

**មាត្រា៦៤ ..**

ការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់របស់ខ្លួន។

**មាត្រា៦៥ ..**

ការបំពេញមុខងារជាអ្នកសាងសង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់របស់ខ្លួន។

**មាត្រា៦៦ ..**

អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី) ថ្នាក់របស់ម្ចាស់សំណង់បានឡើយ។

សមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានឡើយ។

## ជំពូកទី១៦

## កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៦៧ ..**

កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងអប្បបរមាដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យានិងកាលបរិច្ឆេទនិងរបៀបនៃការទូទាត់
- ការធានារបស់ភាគីនៃកិច្ចសន្យាចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌបច្ចេកទេសនិងលក្ខខណ្ឌសុវត្ថិភាពនៃការងារ
- លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬឧបករណ៍និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារសាងសង់ឬរុះរើនិងសម្រាប់បំពាក់លើសំណង់
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងឬបញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយការងារ
- លិខិតអះអាងអំពីអនុលោមភាពនៃគម្រោងប្លង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើតាមបទប្បញ្ញត្តិជាធរមាន
- កាលបរិច្ឆេទចាប់ផ្ដើមនិងបញ្ចប់ការងារនិងកាលបរិច្ឆេទប្រគល់ទទួល

- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

**មាត្រា៦៨ ..**

ចំពោះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន ខដែលរំលោភបំពានត្រូវទុកជាមោឃៈ។

ខដែលរំលោភបំពាននៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន មានដូចខាងក្រោម៖

១. ខដែលតម្រូវឱ្យម្ចាស់សំណង់ផ្តល់អាណត្តិឱ្យអ្នកម៉ៅការស្វែងរកកម្ចីចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់។

២. ខដែលតម្រូវឱ្យម្ចាស់សំណង់ធ្វើការទូទាត់តម្លៃនៃកិច្ចសន្យាទាំងស្រុងជាមុនដើម្បីឱ្យអ្នកម៉ៅការប្រគល់សំណង់មកម្ចាស់សំណង់។

៣. ខដែលហាមឃាត់ម្ចាស់សំណង់ឬតំណាងមិនឱ្យចូលពិនិត្យក្នុងការដ្ឋាន មុនការទូទាត់តម្លៃនៃកិច្ចសន្យាក្នុងដំណាក់កាលនីមួយៗនិងមុនការប្រគល់ទទួល។

៤. ខដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តការងារសាងសង់ឬរុះរើ តាមលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ដែលលក្ខខណ្ឌបច្ចេកទេសមានការប្រែប្រួលធ្ងន់ធ្ងរខុសពីលក្ខខណ្ឌបច្ចេកទេសនៃគម្រោងសាងសង់ ជួសជុល ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យា។

៥. ខដែលដោះបន្ទុកអ្នកម៉ៅការពីកាតព្វកិច្ចអនុវត្តការងារពេញលេញតាមពេលកំណត់ក្នុងកិច្ចសន្យាដោយទទួលស្គាល់មូលហេតុនៃការយឺតយ៉ាវផ្សេងៗ លើកលែងតែមូលហេតុប្រធានសក្តិនិងមូលហេតុដែលបង្កដោយម្ចាស់សំណង់ផ្ទាល់។

**មាត្រា៦៩ ..**

ភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ចឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដូចខាងក្រោម៖

១. លទ្ធកម្មដីឬសិទ្ធិប្រត្យក្សដែលអនុញ្ញាតឱ្យសាងសង់ ក្នុងករណីដែលម្ចាស់សំណង់ទទួលបានការសន្យាលក់។

២. ការទទួលបានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ឬការអនុញ្ញាតផ្សេងទៀតរបស់អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវបញ្ជាក់កាលបរិច្ឆេទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យបានច្បាស់លាស់។

៣. ការទទួលបានកម្ចីដើម្បីធ្វើហិរញ្ញប្បទានដល់ការងារសាងសង់ឬរុះរើ។

៤. ការទទួលបាននូវការធានារ៉ាប់រងចំពោះការខូចខាតបង្កដោយការងារសាងសង់ឬរុះរើ។

៥. ការទទួលបាននូវការធានាការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ការដ្ឋានសំណង់។

**មាត្រា៧០ ..**

ករណីយកិច្ចសម្រេចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះបើដោយគ្មានវិការៈមានដូចខាងក្រោម៖

១. ការងារសាងសង់ត្រូវបានអនុវត្តស្របតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងសេចក្ដីណែនាំជាធរមានដទៃទៀត។

២. ការងារសាងសង់ត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រសមស្របនិងប្រកបដោយសមត្ថភាពជំនាញ។

៣. សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវសមស្របតាមមុខងារប្រើប្រាស់អនុលោមតាមគម្រោងប្លង់និងមានគុណភាពត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេស។

៤. សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវតែជាសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ថ្មី លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា។

**មាត្រា៧១ ..**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក. ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងឆ្អឹងសំណង់ធ្វើពីបេតុងសរសៃដែក បេតុងដែក ឬដែក។

ខ. ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ. ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

គូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់អាចព្រមព្រៀងគ្នាកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារវែងជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

ការកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារខ្លីជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវចាត់ទុកជាមោឃៈ។

## ជំពូកទី១៧

## ការធានារ៉ាប់រង

**មាត្រា៧២ ..**

អ្នកម៉ៅការសាងសង់ឬរះបើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឬរះបើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះបើ ដើម្បីផ្ដល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារនិងតតិយជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។

**មាត្រា៧៣ ..**

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរះបើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្ដប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរះរើបន្តទាំងអស់។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរះរើជាមួយអ្នកម៉ៅការសាងសង់ឬរះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។

**មាត្រា៧៤ ..**

ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរះរើរបស់គម្រោងអភិវឌ្ឍអចលនវត្ថុ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។

**មាត្រា៧៥ ..**

ប្រភេទនិងទំហំសំណង់ដែលតម្រូវឱ្យមានការធានារ៉ាប់រងចំពោះការងារសាងសង់ឬរះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## **ជំពូកទី១៨**

## **ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់**

**មាត្រា៧៦ ..**

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

**មាត្រា៧៧ ..**

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។

**មាត្រា៧៨ ..**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន។

**មាត្រា៧៩ ..**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

**មាត្រា៨០.-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើៈ

- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ
- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូចខាតបានកើតឡើង។

**មាត្រា៨១.-**

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោមៈ

១. នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។

២. សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

**មាត្រា៨២.-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើៈ

១. រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២. រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះរាជដំណាក់

## ជំពូកទី១៩

## ការដោះស្រាយវិវាទក្នុងវិស័យសំណង់

## ផ្នែកទី១

## ការប្តឹងតវ៉ាក្នុងវិស័យសំណង់

**មាត្រា៨៣ ..**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្តឹងត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបណ្តឹង មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៤ ..**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យ

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

**មាត្រា៨៥ ._**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬអាចប្ដឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្ដឹងតវ៉ា។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ផ្នែកទី២
## ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៨៦ ._**

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការ។

សំណើសុំសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់សម្រេចបដិសេធសំណើសុំសម្រុះសម្រួល គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួលក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៧ ._**

ភាគីឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើនោះ។

សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលវិវាទបានកើតឡើង។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយគូភាគីនៃវិវាទនិងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។

ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដោះស្រាយវិវាទសំណង់អំពីការឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ មុននឹងប្តឹងទៅតុលាការ។

**មាត្រា៨៨ ._**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីមានសំណើសុំសម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។

**មាត្រា៨៩ ._**

គណៈកម្មការដោះស្រាយវិវាទសំណង់មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី២០

## ទោសប្បញ្ញត្តិ

**មាត្រា៩០ ..**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់និងទោសដាក់ពន្ធនាគារ។

**មាត្រា៩១ ..**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩២ ..**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យសំណង់។

**មាត្រា៩៣ ..**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះរូបវន្តបុគ្គលដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញមុខងារប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៤ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៥ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យដោយគ្មានអាជ្ញាបណ្ណ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៦ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៧ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៣(បី)ខែ និងពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទីពីររបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

**មាត្រា៩៨ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលបានប្រើឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយដែលកំណត់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៩ ..**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្ដាលឱ្យមានរបួសឬបណ្ដាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០០ ..**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសាងសង់ដែលបានសាងសង់ឬរុះរើមិនអនុលោមតាមគម្រោងប្លង់និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្ដាលឱ្យមានរបួសឬបណ្ដាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០១ ..**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៣០ ០០០ ០០០(សាមសិបលាន)រៀលទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលបានបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់ឬរុះរើថាត្រឹមត្រូវ ដែលតាមជាក់ស្ដែង គម្រោងប្លង់ឬការងារសាងសង់ឬរុះរើនោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយបណ្ដាលឱ្យមានរបួសឬបណ្ដាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០២ ..**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្ដាលឱ្យមានរបួសឬបណ្ដាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០៣ ..**

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើអំពើនេះបណ្ដាលឱ្យមានការកាត់អវយវៈឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះបណ្ដាលឱ្យមានមនុស្សស្លាប់។

**មាត្រា១០៤ ៈ**

ត្រូវផ្តន្ទាទោសដូចមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់នេះ កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់។

**មាត្រា១០៥ ៈ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀលទៅ៨០ ០០០ ០០០(ប៉ែតសិបលាន) រៀល ចំពោះនីតិបុគ្គលណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានអាជ្ញាបណ្ណ។

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ ០០០ ០០០(ហុកសិបលាន)រៀលទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១. ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។
២. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។
៣. ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។
៤. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។
៥. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។
៦. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី២១

## អន្តរប្បញ្ញត្តិ

**មាត្រា១០៦ ៈ**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ម្ចាស់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ត្រូវមកដាក់ពាក្យស្នើសុំ

វិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងរយៈពេលកំណត់ខាងលើ រាល់ទោសប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបន្តអនុវត្តចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន។

**មាត្រា១០៧.-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០៨.-**

ក្រោយច្បាប់នេះចូលជាធរមានក្នុងរយៈពេល២(ពីរ)ឆ្នាំ មន្ទីរពិសោធន៍សំណង់ដែលបាននិងកំពុងប្រតិបត្តិការឬប្រកបអាជីវកម្មត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៩.-**

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចដកយកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាពឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។

អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

លក្ខខណ្ឌនិងនីតិវិធីនៃការតម្កល់ប្រាក់ ការដកប្រាក់តម្កល់ និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ទៅតាមប្រភេទនៃអាជ្ញាបណ្ណដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី២២
## អវសានប្បញ្ញត្តិ

**មាត្រា១១០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១ ..**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

នស/រកម.១១១៩.០២៦

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសំណង់

## សទ្ទានុក្រម

១. **ការងារសំណង់**(construction work) សំដៅដល់ការងារសិក្សាគម្រោងប្លង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២. **ការងារសិក្សាគម្រោងប្លង់**(design work) សំដៅដល់ការងារគូរប្លង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្តីណែនាំបច្ចេកទេស និងការងារគូរប្លង់លម្អិត។

៣. **ការងារវាស់វែង**(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើឋានលេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្លង់ និងការងារសាងសង់។

៤. **ការងារសាងសង់**(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការដំឡើង។

៥. **ការងារជួសជុល**(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៦. **ការងារកែប្រែ**(modification work) សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៧. **ការងាររុះរើ**(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

៨. **ការងារត្រួតពិនិត្យនិងបញ្ជាក់**(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

៩. **ការងារសិក្សាពិសោធ**(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកវិស្វកម្មសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

១០. **ការងារគ្រប់គ្រងគម្រោងសាងសង់**(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រងគម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

១១. **ការដកហូត**(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ដោយអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ច។

១២. **កិច្ចសន្យាម៉ៅការសាងសង់**(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ឬរះរើបន្តដើម្បីអនុវត្តការងារសាងសង់ឬរុះរើ។

១៣. **គម្រោងប្លង់**(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់ មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្ដីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ឬរុះរើនិងការប្រើប្រាស់សំណង់។

១៤. **តម្លៃនៃកិច្ចសន្យា**(contract fee) សំដៅដល់កម្រៃឬតម្លៃថ្លៃដទៃទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

១៥. **ប្រធានសក្តិ**(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

១៦. **បទប្បញ្ញត្តិបច្ចេកទេសសំណង់**(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេស លក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ញា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

១៧. **បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម**(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដីផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

១៨. **បន្ទុក**(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

១៩. **បរិក្ខារសំណង់**(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ជើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្ដើរយន្ត ទុយោ។

២០. **ផលិតផលសំណង់**(construction product) សំដៅដល់ផលិតផលសម្រេចឬពាក់កណ្ដាលសម្រេចដែលកើតចេញពីការបង្កើតឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង [illegible]សី ស្នាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតការ៉ូ។

២១. **ផលិតករ**(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍[illegible]ផលិតផលឬជាអ្នកលក់។

២២- **ម្ចាស់សំណង់**(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

២៣- **មន្ត្រីត្រួតពិនិត្យសំណង់**(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២៤- **វិការៈ**(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

២៥- **វិញ្ញាបនបត្រប្រើប្រាស់សំណង់**(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

២៦- **សំណង់ដែលមានសភាពគ្រោះថ្នាក់**(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

២៧- **សំណង់**(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

២៨- **សម្ភារៈសំណង់**(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

២៩- **អ្នកសាងសង់**(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬក្រុមជាងសំណង់។

៣០- **អ្នកអភិវឌ្ឍអចលនវត្ថុ**(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

៣១- **អាជ្ញាធរមានសមត្ថកិច្ច**(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣២- **អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

៣៣- **អ្នកជំនាញក្នុងវិស័យសំណង់**(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្តុះបណ្តាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធក្នុងការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤. អ្នកគ្រប់គ្រងសំណង់(building manager) សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *